[08]

# Vegetarianism

**Q.** ***Buddhists should be vegetarians, shouldn't they?***

**A.** Not necessarily. The Buddha was not a vegetarian. He did not teach his disciples to be vegetarians and even today, there are many good Buddhists who are not vegetarians.

**Q.** ***If you eat meat you are indirectly responsible the death of a creature. Isn't that breaking the first precept?***

**A.** It is true that when you eat meat, you are indirectly and partially responsible for killing a creature but the same is true when you eat vegetables. The farmer has to spray his crop with insecticides and poisons so that the vegetables arrive on your dinner plates without holes in them. And once again, animals have been used to provide the leather for your belt or handbag, oil for the soap you use and a thousand other products as well. It is impossible to live without, in some way, being indirectly responsible for the death of some other beings. This is just another example of the First Noble Truth, ordinary existence is suffering and unsatisfactory. When you take the First Precept, you try to avoid being directly responsible for killing beings.

សរសេរដោយ **ព្រះភិក្ខុធម្មិកៈ** December 23, 2003

ភាគ ៨

## មំសវិរត្តិ ឬ ការហូបម្ហូបបួស

**ប្ុ.** *ពុទ្ធសាសនិកជនគួរតែមិនបរិភោគសាច់ មែនទេ?*

**ទិ.** មិនចាំបាច់ទេ។ ព្រះពុទ្ធបរមគ្រូមិនមែនជាអ្នកមិនបរិភោគសាច់ទេ។ ព្រះអង្គមិនបានបង្រៀនសាវ័កទាំងឡាយរបស់ព្រះអង្គជាមំសវិរត្តិឡើយ ហើយទោះបីសព្វថ្ងៃនេះមានពុទ្ធសាសនិកជនដ៏ល្អជាច្រើនដែលមិនមែនជាមំសវិរត្តិ ។

**ប្ុ.** *បើអ្នកបរិភោគសាច់ គឺអ្នកត្រូវទទួលខុសត្រូវដោយត្រង់នូវការសំឡាប់សត្វទាំងឡាយ។ តើនោះមិនមែនជាការប្រព្រឹត្តខុសសីលទីមួយឬ?*

**ទិ.** វាជារឿងពិតនៅពេលដែលអ្នកបរិភោគសាច់ អ្នកគឺទទួលខុសត្រូវក្នុងការសំឡាប់សត្វមួយផ្នែកនិងដោយប្រយោល តែក៏ដូចគ្នាដែរនៅពេលអ្នកបរិភោគបន្លែ។ អ្នកចំការត្រូវតែបាញ់ថ្នាំពូជផលរបស់គាត់ដោយថ្នាំបំផ្លាញសត្វល្អិតនិងថ្នាំពិស ដូច្នេះធ្វើឱ្យបន្លែមកដល់ចានម្ហូបល្ងាចរបស់អ្នកដោយគ្មានស្លឹកប្រហេងប្រហោង។ ហើយជាថ្មីម្តងទៀត សត្វពាហនៈត្រូវបានគេប្រើដើម្បីយកស្បែកធ្វើខ្សែក្រវាត់ឬកាបូបយួររបស់អ្នក ខ្លាញ់យកធ្វើសាប៊ូឱ្យអ្នកប្រើនិងទំនិញរាប់ពាន់ប្រភេទផងដែរ។ ម្យ៉ាងវិញទៀត វាពិតជាពិបាកនឹងរស់នៅដោយគ្មានទំនួលខុសត្រូវសំឡាប់ជីវិតសត្វដទៃខ្លះដោយប្រយោលនោះទេ។នេះគ្រាន់តែជាឧទាហរណ៍មួយទៀតនៃអរិយសច្ចទីមួយ សភាវៈសាមញ្ញធម្មតាគឺសេចក្តីទុក្ខនិងភាពមិនពេញចិត្ត។ នៅពេលដែលអ្នកសមាទានសីលដំបូង អ្នកព្យាយាមជៀសវាងទទួលខុសត្រូវសំឡាប់ជីវិតគេដោយត្រង់ ។



បកប្រែដោយ**ព្រះភិក្ខុខេមានន្ទោ សេង សុភ័ណ** (បរិញ្ញាបត្រទស្សនវិជ្ជា)

**Q.** ***Mahayana Buddhists don't eat meat?***

**A.** That is not correct. Mahayana Buddhism in China laid great stress on being vegetarian but both the monks, laymen and women of the Mahayana tradition in Japan and Tibet usually eat meat.

**Q.** ***But I still think that a Buddhist should be vegetarian.***

**A.** If there was a man who was a very strict vegetarian but who was selfish, dishonest and mean, and another man who was not a vegetarian but who was thoughtful of others, honest, generous and kind, which of these two people would be the better Buddhist?

**Q.** ***The person who was honest and kind.***

**A.** Why?

**Q.** ***Because such a person obviously has a good heart.***

**A.** Exactly. One who eats meat can have a pure heart just as one who does not eat meat can have an impure heart. In the Buddha's teachings, the important thing is the quality of your heart, not the contents of your diet. Many Buddhists take great care never to eat meat but they are not concerned about being selfish, dishonest, cruel or jealous.

**ឬ.** *ពុទ្ធសាសនិកជននិកាយមហាយានមិនបរិភោគសាច់ទេ?*

**ទិ.** នោះគឺមិនត្រឹមត្រូវទេ។ ព្រះពុទ្ធសាសនានិកាយមហាយានក្នុងប្រទេសចិនតឹងតែងណាស់ក្នុងការបដិបត្តិជាមំសវិរត្តិ តែព្រះសង្ឃ ឧបាសក ឧបាសិកា និកាយមហាយានទាំងនៅក្នុងប្រទេសជប៉ុននិងទីបេ ជាធម្មតាគឺបរិភោគសាច់ ។

**ឬ.** *តែខ្ញុំនៅតែគិតថាពុទ្ធសាសនិកជនគួរតែជាអ្នកមំសវិរត្តិ ។*

**ទិ.** បើមានមនុស្សម្នាក់ដែលជាអ្នកតឹងតែងក្នុងការមិនបរិភោគសាច់តែជាអ្នកអាត្មានិយម មិនស្មោះត្រង់និងកាចសាហាវ ហើយមនុស្សម្នាក់ទៀតដែលមិនមែនជាអ្នកមិនបរិភោគសាច់ តែជាអ្នកដែលមានសុភវិនិច្ឆ័យចំពោះអ្នកដទៃ ស្មោះត្រង់ ចិត្តទូលាយនិងចិត្តល្អ តើមនុស្សទាំងពីរប្រភេទនេះ ម្នាក់ណាដែលជាពុទ្ធសាសនិកជនល្អជាងគេ?

**ឬ.** *មនុស្សដែលជាអ្នកមានសេចក្ដីស្មោះត្រង់និងសន្ដានចិត្តល្អ ។*

**ទិ.** ព្រោះហេតុអ្វី?

**ឬ.** *ពីព្រោះមនុស្សប្រភេទនោះមានសន្ដានចិត្តល្អជាក់ស្ដែង ។*

**ទិ.** ពិតប្រាកដហើយ។ មនុស្សដែលបរិភោគសាច់អាចមានសន្ដានចិត្តបរិសុទ្ធិ ដូចគ្នានឹងមនុស្សម្នាក់ដែលមិនបរិភោគសាច់អាចមានសន្ដានចិត្តមិនបរិសុទ្ធិ។ ក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ វត្ថុដែលសំខាន់គឺបេះដូងរបស់អ្នក មិនមែនជាបញ្ជីរតមអាហាររបស់អ្នកទេ។ ពុទ្ធសាសនិកជនជាច្រើនយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការមិនហូបសាច់ តែពួកគេមិនចាប់អារម្មណ៏អំពីភាពជាអាត្មានិយម មិនស្មោះត្រង់ កាចសាហាវនិងចិត្តឫស្យា។

They change their diet which is easy to do, while neglecting to change their hearts, which is a difficult thing to do. So whether you are a vegetarian or not, remember that the purification of the mind is the most important thing in Buddhism.

ពួកគេប្តូរការតមអាហាររបស់គេដែលងាយនឹងធ្វើ ក្នុងខណៈដែលព្រងើយកន្តើយរឿងការផ្លាស់ប្តូរបេះដូងរបស់គេ ដែលជារឿងលំបាកនឹងផ្លាស់ប្តូរ។ ដូច្នេះទោះបីអ្នកជាមំសាវិរត្តិ ឬទេនោះ ចូរចងចាំទុកថាភាពបរិសុទ្ធិនៃចិត្តគឺជាវត្ថុសំខាន់បំផុតក្នុងព្រះពុទ្ធសាសនា ។